## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

- សាលក្រមព្រហ្មទណ្ឌ លេខ៖ ៦៥ "ឈ"
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣
- សំណុំរឿងព្រហ្មទណ្ឌ លេខ៖ ៨៨៩
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១
- សំណុំរឿងជំនុំជម្រះ លេខ៖ ១៣៥
ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកំពង់ធំ
នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣

ដែលមានសមាសភាពដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ធំ
ឯកឧត្ត[redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ធំ
លោក [redacted] ជាចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ធំ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨៨៩ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដែលមាន៖

**ជនជាប់ចោទ៖**

១.ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្នរស់នៅភូមិ[redacted] ខេត្តកំពង់ចាម ។ (ក្រៅឃុំ)

- ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន លេខ៖ ៣៩១ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ។
- ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន លេខ៖ ៣៩២ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ។/



Scanned with CamScanner

- ដីកាសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ លេខ៖ ៧៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។
- ដីកាបង្គាប់ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ លេខ៖ ៤៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០២២ ។
- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ៖ ៧៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។

២.ឈ្មោះ [redacted] យេប ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្នរស់នៅភូមិ[redacted] ខេត្តកំពង់ចាម ។ (ក្រៅឃុំ)

- ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន លេខ៖ ៣៩២ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ។
- ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន លេខ៖ ៣៩៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ។
- ដីកាសម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ លេខ៖ ៧២ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។
- ដីកាបង្គាប់ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ លេខ៖ ៤៤ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០២២ ។
- ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ លេខ៖ ៧៤ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ ។

ត្រូវបានបញ្ជូនមកសាលាដំបូងខេត្តកំពង់ធំ តាមដីកាដំណោះស្រាយលេខ៖ ៩៥២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តកំពង់ធំ ដើម្បីជំនុំជម្រះពីបទ៖ **កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ** ប្រព្រឹត្តនៅតំបន់លោកម៉ៅ ត្រង់ចំណុចនិយាមកា (៥៦៨១៦៦-១៤១៤២៧៤) ស្ថិតនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ។

<u>មេធាវី៖</u>

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

## ១. អង្គហេតុដែលប្ដឹងមកតុលាការមានដូចតទៅ

យោងតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញនូវអង្គហេតុ ដូចតទៅ៖ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង២និង២៩នាទីរសៀល មន្ត្រីឧទ្យានុរក្សដែលប្រចាំនៅដែនជម្រកសត្វព្រៃព្រៃឡង់ ភូមិសាស្ត្រខេត្តកំពង់ធំ ចំនួន០៤នាក់ បានល្បាតតំបន់លោកតាម៉ៅ ត្រង់ចំណុចនិយាមកា (៥៦៨១៦៦-១៤១៤២៧៤) ស្ថិតនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ បានលឺសំឡេងជនល្មើសមានគ្នាចំនួន០៥នាក់ កំពុងធ្វើសកម្មភាពកាប់ដីព្រៃយកធ្វើជាកម្មសិទ្ធ ដោយបានឃាត់ខ្លួនបានចំនួន០២នាក់ មានឈ្មោះ [redacted] សុខា ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤០



Scanned with CamScanner

ឆ្នាំ ចំណែកឈ្មោះ ឡេង ឈ្មោះ ចេក និងឈ្មោះ ហង្ស បានរត់គេចខ្លួនបាត់ ។ ចំណែកទីតាំងដែលជនសង្ស័យបានកាប់ឆ្ការគ្រួសព្រៃបុស្សនេះ អស់ប្រហែល ៤ហិចតា ទាំងស្នាមកាប់ចាស់ ស្នាមកាប់ថ្មី ។ ក្រោយពីបានសាកសួរចប់សព្វគ្រប់ហើយ ជនសង្ស័យទាំងពីរបានសារភាពថា ជាអ្នកស៊ីឈ្នួលឱ្យថៅកែឈ្មោះ ម៉ៅ តែប៉ុណ្ណោះ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ១២០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ។

-បានឃើញ ដីកាដំណោះស្រាយ លេខ៖ ៩៥២ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ធំ។

-បានឃើញ ដីកាសម្រេចចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះ លេខ៖ ១៨៣ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ ។

## ២. ពេលសវនាការ

- តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខា ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការថា៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១ ខ្លួន និងបក្ខពួក៤នាក់ មានឈ្មោះ ចេក ភេទប្រុស អាយុប្រហែល ៣០ឆ្នាំជាង, ឈ្មោះ ឡេង ភេទប្រុស អាយុប្រហែល៤០ឆ្នាំ, ឈ្មោះ ហង្ស ភេទប្រុស អាយុប្រហែល៣០ឆ្នាំ, ឈ្មោះ យេន យេប ភេទប្រុស អាយុ៤០ឆ្នាំ ហើយខ្លួន និងបក្ខពួកបានស្នាក់ នៅចំការឈ្មោះ ម៉ៅ ចំនួន០៦យប់ ។ ហើយឈ្មោះ ម៉ៅ ជាម្ចាស់ដែលពួកខ្លួនជាអ្នកស៊ីឈ្នួលកាប់ឆ្ការឲ្យគាត់ ដោយមិនគិតពីចំនួនហិចតានោះទេ ហើយម្ចាស់ឈ្មោះ ម៉ៅ គាត់គិតកម្រៃក្នុងមួយហិចតា ចំនួន ៥៥០០០០(ហាសិបប្រាំម៉ឺនរៀល) មកឱ្យពួកខ្លួន ។ លុះព្រឹកឡើងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១ ពួកខ្លួនបានចូលទៅកាប់ព្រៃតាមការចង្អុលបង្ហាញរបស់ម្ចាស់ឈ្មោះ ម៉ៅ ហើយពួកខ្លួនបានកាប់ឆ្ការព្រៃ (តែមិនមែនព្រៃធំៗនោះទេលក្ខណៈព្រៃបស់មួយៗ) ដោយប្រើកាំបិតផ្គាក់ម្នាក់មួយ រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ពួកខ្លួនបានកាប់ចំនួន៤ហិចតា លុះដល់ម៉ោង២រសៀលពួកខ្លួនកំពុងឆ្ការ ស្រាប់តែសមត្ថកិច្ចមក ចុះឃាត់ខ្លួនរូបខ្លួន និងឈ្មោះ [redacted] យេប បាន ចំណែកឯអ្នកផ្សេងទៀតបានរត់គេចខ្លួនបាត់ ។

- តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] យេប ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការថា៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០២១ ខ្លួននិងបក្ខពួក០៤នាក់ មានឈ្មោះ ចេក ភេទប្រុស អាយុប្រហែល៣០ឆ្នាំជាង, ឈ្មោះ ឡេង ភេទប្រុស អាយុប្រហែល៤០ឆ្នាំ, ឈ្មោះ ហង្ស ភេទប្រុស អាយុប្រហែល ៣០ឆ្នាំ, ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ៣២ឆ្នាំ ដែលខ្លួននិងបក្ខពួកបានស្នាក់នៅចំការរបស់ឈ្មោះ ម៉ៅ ចំនួន៦យប់ ។ ហើយឈ្មោះ ម៉ៅ ភេទប្រុស អាយុប្រហែល៥០ឆ្នាំជាង រស់នៅភូមិសំពោង ឃុំ(មិនស្គាល់) ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជាម្ចាស់ដែលពួកខ្លួនស៊ីឈ្នួលកាប់ឆ្ការឲ្យគាត់ ដោយមិនគិតពីចំនួនហិចតានោះទេ



Scanned with CamScanner

ពួកខ្លួនកាប់បានចំនួនប៉ុណ្ណា គិតលុយឱ្យប៉ុណ្ណឹង ហើយម្ចាស់ឈ្មោះ ម៉ៅ គិតកម្រៃក្នុងមួយហិចតា ចំនួន ៥៥០០០០(ហាសិបប្រាំម៉ឺនរៀល) មកឱ្យពួកខ្លួន ។ លុះព្រឹកឡើងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១ ពួកខ្លួនបានចូលទៅកាប់ព្រៃ តាមការចង្អុលបង្ហាញរបស់ម្ចាស់ឈ្មោះ ម៉ៅ ហើយព្រៃដែលខ្លួនបានកាប់ឆ្ការមិនធំនោះទេ លក្ខណៈព្រៃរបស់មួយៗ ដោយប្រើកាំបិតផ្គាក់ម្នាក់មួយ រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ពួកខ្លួនបានកាប់បានចំនួន៤ហិចតាជាង លុះដល់ម៉ោង២ រសៀល ស្រាប់តែសមត្ថកិច្ចចុះឃាត់ខ្លួន រូបខ្លួន និងឈ្មោះ [redacted] សុខា បាន ចំណែកអ្នកផ្សេងរត់គេចខ្លួនបាន ។

- **តាមអំណានចម្លើយសាក្សីឈ្មោះ** [redacted] **វ៉ាន់ ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការ** ថា៖ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង០២និង២៥នាទីរសៀល ខ្លួនបានដឹកនាំមន្ត្រីឧទ្យានុរក្ស០២នាក់ ចុះល្បាតនៅដែនសត្វព្រៃ ព្រៃឡង់ ។ ស្រាប់តែប្រទះឃើញមានជនល្មើសកំពុងកាប់រានដីព្រៃ នៅចំណុចលោកតាម៉ៅ និយាមកា(៥៦៨១៦៦-១៤១៤២៧៤) ស្ថិតនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ។ បន្ទាប់ពីបានឃើញ ក្រុមជនល្មើសចំនួន០៥នាក់ កំពុងធ្វើការកាប់រានដីព្រៃ ខ្លួនបានឱ្យកម្លាំងព័ទ្ធជុំវិញ ដើម្បីធ្វើការឃាត់ខ្លួន ប៉ុន្តែក្រុមជនល្មើសបានដឹងខ្លួនមុន នៅពេលឃើញខាងកម្លាំងឧទ្យានុរក្ស ក៏នាំគ្នារត់គេចខ្លួនអស់០៣នាក់ នៅសល់០២នាក់ ហើយក៏បានសួរចម្លើយ ឃើញថាជនល្មើសទាំង០២នាក់នោះបានសារភាពថា ខ្លួនពិតជាបានកាប់រានដីព្រៃពិតមែន ប៉ុន្តែពួកខ្លួន គឺស៊ីឈ្នួលកាប់ឲ្យឈ្មោះ ម៉ៅ រស់នៅឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ក្នុងតម្លៃ០១ហិចតា ៥៥ម៉ឺនរៀល ។ ខ្លួនសូមបញ្ជាក់ថា ជនល្មើសដែលឃាត់ខ្លួន ជាអ្នកចំណាក់ស្រុកស៊ីឈ្នួលគេមកកាប់ដីព្រៃ តែប៉ុណ្ណោះ មិនមែនជាប្រជាពលរដ្ឋមានដីនៅតំបន់នោះទេ ។ នៅពេលឃាត់ខ្លួនជនល្មើសបាន ខ្លួនឃើញមានឧបករណ៍សម្រាប់កាប់រានដីព្រៃ មាន កាំបិតផ្គាក់ចំនួន០២ដើម ពុំមានរណាយន្ត ឬគ្រឿងយន្តនៅទីនោះទេ ទីតាំងកាប់រាននោះ ពុំមានដើមឈើធំៗទេ មានតែព្រៃបុស្សរុះតែប៉ុណ្ណោះ ទីតាំងនោះពុំមានជាប់ព័ន្ធនឹងដីតំបន់១,២,៣ ដែលជាដីព្រៃលិចទឹកនោះទេ ។ រីឯទំហំផ្ទៃដី ដែលជនល្មើសកាប់រាននោះ ខាងការិយាល័យដែនជម្រកព្រៃឡង់ មិនទាន់បានផ្តល់ទំហំមកខ្លួនទេ (ខ្លួនបានចុះចុចកំណត់ទីតាំងអស់ហើយ) តាមខ្លួនស្មានទំហំប្រហែល៤ហិចតា ។ ខ្លួនសូមបញ្ជាក់ថា ទីតាំងដីដែលកាប់រាននោះ (ដែនជម្រក សត្វព្រៃ ព្រៃឡង់) តាមអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ បានផ្ទេរមកឱ្យខាងមន្ទីរបរិស្ថានខេត្តកំពង់ធំ ជាអ្នកគ្រប់គ្រង ។ ហើយនៅទីតាំងដែលកាប់រាននោះខាងមន្ត្រីបានដាក់ស្លាកសម្គាល់ថា ហាមកាប់រានដីព្រៃ ផងដែរ ។

- **តាមអំណានចម្លើយសាក្សី (មេភូមិអូរក្រពើ) ឈ្មោះ** [redacted] **សំអឿន ឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការ**ថា៖ ខ្លួនធ្វើជាមេភូមិអូរក្រពើនៅចុងឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ន ចំពោះទីតាំងកើតហេតុ ខ្លួនស្គាល់គឺនៅតំបន់លោកតាម៉ៅ ស្ថិតនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ជាតំបន់ព្រៃឡង់ ខ្លួនស្គាល់តាមខាងមន្ត្រីជំនាញ ។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ខ្លួនមិនបានចូលរួមជាមួយខាង



Scanned with CamScanner

មន្ត្រីជំនាញចុះបង្ក្រាបបទល្មើសទេ ។ ចំពោះទីតាំងលោកតាម៉ៅពីមុន ស្ថិតនៅភូមិស្លែង ក្រោយមកលោកអភិបាលស្រុកឱ្យខ្លួនធ្វើតារាង ដាក់តំបន់លោកតាម៉ៅនោះ ចូលទៅភូមិអូរក្រពើវិញ ។ ហើយនៅតំបន់នោះ ខ្លួនបានឃើញ ប្រជាពលរដ្ឋជាច្រើនប្រហែល ៦២គ្រួសារ ចូលទៅអាស្រ័យផល នៅទីនោះ ។ ហើយសព្វថ្ងៃឈ្មោះ ម៉ៅ មិនបានគ្រប់គ្រងដីនៅទីនោះទេ ។ ចំពោះជនត្រូវចោទទាំង៦នាក់ខាងលើ ខ្លួនស្គាល់តែឈ្មោះ ម៉ៅ តែម្នាក់ទេ ក្រៅពីនោះខ្លួនពុំស្គាល់ទេ ។ ខ្លួនស្គាល់ដោយសារសព្វថ្ងៃឈ្មោះ ម៉ៅ មានចំការនៅជិតទីតាំងកើតហេតុដែរ ហើយចំពោះអត្តសញ្ញាណរបស់ឈ្មោះ ម៉ៅ ខ្លួននឹងផ្តល់ឯកសារជូនលោកចៅក្រមនៅពេលក្រោយ ។ ខ្លួនសូមបញ្ជាក់បន្ថែមថា ចំពោះទីតាំងដីកើតហេតុ កាលពីមុនមានព្រៃដុះធំៗ តាំងពីមុនខ្លួនធ្វើជាមេភូមិអូរក្រពើ ក្រោយមកឈ្មោះ ម៉ៅ ចុះទៅកាប់រានទីនោះ ក្នុងឆ្នាំ២០២១ ពុំមានព្រៃដុះធំៗទេ គឺដីបុស្ស (ដីព្រៃដែលមានដើមឈើតូចៗ និងជាដីព្រៃដែលគេធ្លាប់កាប់រានម្តងហើយ) ។

- តាមអំណានចម្លើយសាក្សី (មេភូមិត្បែង) ឈ្មោះ [redacted] សុត ឆ្លើយនៅជំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការថា៖ ខ្លួនជាមេភូមិត្បែង ឃុំបឹងល្វា តាំងពីឆ្នាំ២០០៤ រហូតដល់សព្វថ្ងៃ ហើយចំពោះទីតាំងកាប់រានឈ្មោះ លោកតាម៉ៅ ខ្លួនមិនដែលស្គាល់ទេ ។ ចំពោះឈ្មោះ ម៉ៅ ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិសំពោង ឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ,ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ រស់នៅ ភូមិល្វារក្សត្នោត ឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម, ឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិល្វារក្សត្នោត ឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម, ឈ្មោះ ចេក ភេទប្រុស អាយុប្រហែល៣៩ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិល្វារក្សត្នោត ឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម, ឈ្មោះ ឡេង ភេទប្រុស អាយុ២៦ ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិល្វារក្សត្នោត ឃុំបែកអន្លង់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ជនទាំង០៦នាក់ខាងលើនេះខ្លួនមិនបានស្គាល់នោះទេ ហើយក៏មិនមែនជាអ្នករស់នៅភូមិត្បែងដែរ ។

- ក្រឡាបញ្ជី អានកំណត់ហេតុដកហូតឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ របស់រដ្ឋបាលព្រៃឈើកំពង់ថ្ម បានបញ្ជាក់ថាមាន៖ កាំបិតផ្គាក់ចំនួន ០២ផ្លែ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] យេប ប្រើប្រាស់ដើម្បីធ្វើការកាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ដោយគ្មានលិខិតអនុញ្ញាត ។

- តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ និងអំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងពិនិត្យភស្តុតាងនានា ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ដូចនេះតំណាងអយ្យការស្នើសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរ លេខ៖ ១២០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដដែល ។



Scanned with CamScanner

- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋាន ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ក្រោយពីបានស្តាប់អំណានចម្លើយរបស់កូនក្តីខ្លួន និងអំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ខ្លួនស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនទាំងពីរ ផង ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខា ៖ មិនបានបង្ហាញខ្លួននៅក្នុងអង្គសវនាការទេ ។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] យេប ៖ មិនបានបង្ហាញខ្លួននៅក្នុងអង្គសវនាការទេ ។

  - ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
  - ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
  - ក្រោយពីបានស្តាប់អំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌
  - ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
  - ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
  - ក្រោយពីបានពិនិត្យកស្តុតាងនានាក្នុងសំណុំរឿង

## ៣.សំអាងហេតុ

ក. យល់ឃើញថា៖ ផ្អែកតាមដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយ បានបង្ហាញឲ្យឃើញថា កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ពិតជាមានករណី កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ ប្រព្រឹត្តនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ ពិតប្រាកដមែន ។

ខ. យល់ឃើញថា៖ តាមអំណានចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ និងផ្អែកទៅតាមអំណានចម្លើយរបស់សាក្សី ព្រមទាំងអំណាន ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ មានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងអង្គហេតុ ដែលបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ ពិតជាបានប្រព្រឹត្តបទល្មើស កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ ពិតប្រាកដមែន ។

គ. យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ ដែលធ្វើសកម្មភាពខាងលើ បានស្តែងចេញមកខាងក្រៅនូវធាតុចេតនា និងជាសកម្មភាពដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយត្រូវបានច្បាប់កំណត់ថា ជាបទល្មើស៖ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។



Scanned with CamScanner

ឃ. យល់ឃើញថា៖ ជនជាប់ចោទ មិនបានបង្ហាញខ្លួនក្នុងអង្គសវនាការទេ ដោយគ្មានមូលហេតុ ទោះបីជាតុលាការបានធ្វើការកោះហៅតាមនីតិវិធី តុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ។

ង. យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ គឺជានីតិជន ហើយពុំមានភស្តុតាង ណាមួយបញ្ជាក់ថា ជនជាប់ចោទនេះ មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះ ជនជាប់ចោទពិតជាមានស្មារតីយល់ដឹងខុសត្រូវ អំពីផលវិបាក តាមផ្លូវច្បាប់ ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

ច. យល់ឃើញថា៖ មានភស្តុតាងនានាគ្រប់គ្រាន់ ដើម្បីប្រកាសថា មានពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យេប ភេទប្រុស អាយុ៤២ឆ្នាំ ដែលបានប្រព្រឹត្តអំពើដែលជាបទ ឧក្រិដ្ឋ ហើយជនជាប់ចោទនេះ ពិតបានប្រព្រឹត្តអំពើ ដូចដែលបានចោទប្រកាន់ ពីបទ៖ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ ប្រព្រឹត្តនៅភូមិស្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

ឆ. យល់ឃើញថា៖ តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ ដោយស្នើសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមផ្លូវច្បាប់ ។ ចំពោះសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានភាពជឿជាក់បានថា អំពើរបស់ជនជាប់ចោទ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ និងតុលាការ យល់ស្របតាមការប្តឹងសុំនេះ ។

ជ. យល់ឃើញថា៖ មេធាវី បានធ្វើសេចក្តីសន្និដ្ឋាន ដោយស្នើសុំមកតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឈ្មោះ អ៊ាវ សុខា និងឈ្មោះ [redacted] យេប ផង ។ ចំពោះសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីគប្បី តុលាការយកមកពិចារណាលើការស្នើសុំនេះ ។

ឈ. យល់ឃើញថា៖ វត្ថុដែលចាប់យក កំណត់ហេតុដកហូតឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ បានបញ្ជាក់ថាមាន៖ កាំបិតផ្គាក់ចំនួន ០២ផ្លែ បានបង្ហាញថា ជាផលដែលបានមកពីបទល្មើស និងជាសម្ភារៈក្នុងការប្រព្រឹត្តបទល្មើស គប្បីតុលាការធ្វើសម្រេចពីការរឹបអូសវត្ថុតាងតាមច្បាប់ តាមបញ្ញត្តិមាត្រា ៥៣ មាត្រា ៦២ មាត្រា ៦៣ និងមាត្រា ២២៩ នៃក្រមព្រហ្មទណ្ឌ ។

## ៤.សេចក្តីសម្រេច

## ហេតុដូច្នេះ សាលាដំបូងខេត្តកំពង់ធំ សម្រេច ៖

១- ផ្តន្ទាទោសលើជនជាប់ចោទ៖

១.១. ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ ៣២ឆ្នាំ (ដែលមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ



Scanned with CamScanner

១.២. ឈ្មោះ [redacted] យេប ភេទប្រុស អាយុ ៤២ឆ្នាំ (ដែលមានសាវតាជាតិខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ

ពីបទ៖ កាប់គាស់ ក្រាបដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធ ប្រព្រឹត្តនៅភូមិត្បែង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២ កថាខណ្ឌ១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។

២- រឹបអូសជាសម្បត្តិរដ្ឋ ចំពោះវត្ថុចាប់យក ដែលមានដូចខាងក្រោម ៖

- កាំបិតផ្គាក់ចំនួន ០២ផ្លែ ។

សាលក្រមនេះ បានធ្វើការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ និងបានប្រកាសជាសាធារណៈ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] យេប ។

ភាគីដែលច្បាប់ផ្តល់សិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់ ។

| ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted] | ហត្ថលេខា និងត្រា៖ [redacted] |

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា៖ [redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១១ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner